# ចូរសង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង

អែលឌើរ យេន ឌី វ៉ិតសុន
ក្រុមនៃពួក 70 នាក់

*ការរៀនចេះសង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាងគឺជាអំណោយទានខាងវិញ្ញាណ ដែលអាចផ្តល់ឱ្យ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។*

នៅក្នុងការឆ្លើយតបនឹងសំណួររបស់ព្យាការី យ៉ូសែប ស្ម៊ីធ ព្រះអម្ចាស់បានបង្រៀនថា: "ហើយគ្មានអ្នកណាអាចជួយក្នុងកិច្ចការនេះបានឡើយ លើកលែងតែអ្នកនោះនឹងបន្ទាបខ្លួន ហើយពោរពេញទៅដោយសេចក្តីស្រឡាញ់ដោយមានសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ដោយសង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង ដែលផ្ទុកផ្តាក់ឱ្យគេថែរក្សា" ។1

ការបង្រៀនឱ្យចេះសង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាងអនុវត្តចំពោះយើងម្នាក់ៗ ។ តើការសង្កត់ចិត្តគឺជាអ្វី? ចុះតើហេតុអ្វីបានជាព្រះអម្ចាស់ចង់ឱ្យយើងចេះសង្កត់ចិត្ត? អត្ថន័យដ៏តូចចង្អៀតប្រហែលជាអាច "អនុវត្តបាន នៅពេលយើងនិយាយដល់ការទទួលទានអាហារ និងទឹក" ។ ពិតណាស់ អត្ថន័យនៃពាក្យការសង្កត់ចិត្តនេះអាចជាការពិពណ៌នាមួយ យ៉ាងល្អចំពោះការគោរពតាមពាក្យគតិបណ្ឌិត ។ នៅពេលខ្លះការសង្កត់ចិត្តអាចសំដៅទៅលើ "ការទប់កំហឹង ឬការបាត់បង់ភាពអត់ធ្មត់របស់នរណាម្នាក់" ។ ទោះជាយ៉ាងណាក្តីន័យនេះ ត្រូវបានប្រើប្រាស់តែមួយចំនួនប៉ុណ្ណោះនៅក្នុងព្រះគម្ពីរ ។

ទស្សនៈខាងវិញ្ញាណ ការសង្កត់ចិត្តគឺជាលក្ខណៈដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់មានព្រះទ័យចង់ឱ្យយើងម្នាក់ៗអភិវឌ្ឍន៍នូវឥរិយាបថនេះ ។ ការរៀនចេះសង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង គឺជាអំណោយទានខាងវិញ្ញាណដែលអាចផ្តល់ឱ្យតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

នៅពេលសាវកប៉ុលពិពណ៌នាអំពីផលផ្លែនៃវិញ្ញាណមួយចំនួនទៅកាន់ប្រជាជនកាឡាទី គឺគាត់លើកឡើងអំពី "សេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព ស្មោះត្រង់ ស្លូតបូត [និង] ដឹងខ្នាត" ។2

នៅពេលប៉ុលសរសេរដល់ទីតុសដោយពិពណ៌នាអំពីឥរិយាបថដ៏ចាំបាច់សំរាប់របស់ប៊ីស្សព ដើម្បីជួយនៅក្នុងការងារនេះ នោះគាត់និយាយថា ប៊ីស្សពម្នាក់ "[មិនត្រូវ]មានចិត្តមានះ ឆាប់ខឹង... [ប៉ុន្តែ] មានចិត្តធូរវិញ ។"3 ការសង្កត់ចិត្ត គឺត្រូវបានប្រើប្រាស់នៅរាល់ការគ្រប់គ្រងការងារសព្វបែបយ៉ាង ឬការអនុវត្តគ្រប់គ្រងខ្លួនឯង ។

នៅពេលអាលម៉ាជាកូន បានបង្រៀននៅលើដែនដីគេឌាន លោកមានប្រសាសន៍ថា: "ខ្ញុំជឿថា អ្នករាល់គ្នាពុំលើកខ្លួនឡើងក្នុងការឆ្មើងឆ្មៃនៃចិត្តអ្នកដែរ មែនហើយខ្ញុំជឿថា អ្នករាល់គ្នាពុំភ្ជាប់ចិត្តទៅលើទ្រព្យសម្បត្តិ និងវត្ថុទាំងឡាយ ដែលឥតប្រយោជន៍នៃលោកិយឡើយ... ។

"ខ្ញុំចង់ឱ្យអ្នករាល់គ្នាបន្ទាបខ្លួន ហើយចុះចូល ហើយសុភាពទន់ភ្លន់ រហ័សធ្វើតាមការល្អពោរពេញទៅដោយការទ្រាំទ្រ និងការអត់ធ្មត់សង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង" ។4

សារលិខិតក្រោយមកទៀតអាលម៉ា បានបង្រៀនដល់កូនប្រុសរបស់គាត់ ស៊ីបឡុន ហើយការបង្រៀននេះបានពង្រីកមកដល់យើងគ្រប់រូបឱ្យ"ឃើញថា កូនប្រយ័ត្នកុំលើកខ្លួនឡើងទៅជាឆ្មើងឆ្មៃ"5 ផ្ទុយទៅវិញ យើងគួរតែ " មានការព្យាយាម ហើយចេះទប់ចិត្តក្នុងគ្រប់ការណ៍ទាំងអស់" ។7 ការសង្កត់ចិត្តមានន័យថា ជាការពិនិត្យទៅលើការរំពឹងទុក និងបំណងប្រាថ្នារបស់យើងដោយប្រុងប្រយ័ត្ន ដើម្បីមានភាពឧស្សាហ៍ព្យាយាម និងភាពអត់ធ្មត់នៅក្នុងស្វែងរកគោលដៅសុចរិតទាំងឡាយ ។

ប៉ុន្មានឆ្នាំកន្លងទៅ ពេលខ្ញុំបើកឡានមកពីធ្វើការវិញ នោះមានឡានអូសធុនកណ្តាលមួយកំពុងធ្វើដំណើរបញ្ច្រាសទិសពីឡានរបស់ខ្ញុំបានរបូតកង់មួយចេញមក ។ កង់ដែលរបូតនោះហោះខ្ទាតឆ្លងកាត់គំនូសកណ្តាលផ្លូវ ។ វាបានខ្ទាតចូលមកខាងផ្លូវរបស់ខ្ញុំដែលជាផ្លូវម្ខាងទៀត ។ ឡានជាច្រើនដែលបើកបរនៅលើផ្លូវនោះបានគេចចេញ ដោយអ្នកបើកបរមិនដឹងកង់ឡាននោះនឹងលោតទៅធ្លាក់ចំទិសដៅណាមួយឡើយ ។ ខ្ញុំបានគេចទៅឆ្វេង ខណៈពេលដែលខ្ញុំគួរតែគេចទៅស្តាំ ហើយនៅទីបំផុតកង់ឡាននោះបានលោតមកប៉ះជ្រុងកញ្ចក់ខាងស្តាំរបស់ខ្ញុំ ។

មិត្តម្នាក់បានទូរស័ព្ទប្រាប់ភរិយារបស់ខ្ញុំពីគ្រោះថ្នាក់នោះ ។ ក្រោយមកនាងបានប្រាប់ខ្ញុំថា ដំបូងនាងគិតថា ខ្ញុំមានរបួស ដោយសារការបែកកញ្ចក់នោះ ។ ជាការពិតណាស់ អំបែងកញ្ចក់បានបែកខ្ទាតមកពេញលើខ្លួនខ្ញុំ ប៉ុន្តែគ្មានស្នាមរបួសដាច់អ្វីបន្តិចឡើយ ។ ប្រាកដណាស់វាមិនមែនដោយសារជំនាញក្នុងការបើកបររបស់ខ្ញុំទេ ប៉ុន្តែដោយសារកញ្ចក់ចំហៀង កូនឡានតូចរបស់ខ្ញុំបានធ្វើឡើងពីកញ្ចក់ដែលលត់យ៉ាងហាប់ ។

កញ្ចក់ដែលលត់យ៉ាងហាប់ ដូចជាដែកដែលលត់ហើយដូច្នេះដែរ ដោយឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យក្នុងការធន់នឹងកំដៅ នោះបានធ្វើឱ្យវាកាន់តែរឹងមាំថែមទៀត ។ ដូច្នេះនៅពេលកញ្ចក់ដែលលត់យ៉ាងហាប់ វារងទម្ងន់ វាមិនងាយបែកទៅជា ចំរៀក១ដែលអាចធ្វើឱ្យយើងមានរបួសនោះទេ ។

ម្យ៉ាងវិញទៀត ព្រលឹងដែលចេះសង្កត់ចិត្ត--- គឺជាមនុស្សម្នាក់ដែលបន្ទាបខ្លួន និងពោរពេញទៅដោយសេចក្តីស្រឡាញ់ -- ហើយក៏ជាមនុស្សដែលរឹងមាំខាងព្រលឹងវិញ្ញាណកាន់តែខ្លាំងផងដែរ ។ ដោយសារភាពរឹងមាំខាងវិញ្ញាណកើនឡើង នោះយើងអាចអភិវឌ្ឍន៍ភាពម្ចាស់ការលើខ្លួនឯង និងរស់នៅដោយ ចេះប្រមាណ ។ យើងរៀនចេះគ្រប់គ្រង ឬទប់កំហឹង ភាពឥតប្រយោជន៍ និងភាពឆ្មើងឆ្មៃរបស់យើង ។ ដោយសារភាពរឹងមាំខាងព្រលឹងវិញ្ញាណកើនឡើង យើងអាចការពារខ្លួនយើងពីគ្រោះថ្នាក់ និងការបំផ្លិចបំផ្លាញពីការញៀននៅក្នុងពិភព លោករបស់យើងនាពេលបច្ចុប្បន្ននេះទៀតផង ។

យើងទាំងអស់គ្នាស្វែងរកភាពសុខសាន្តក្នុងគំនិត និងមានប្រាថ្នាចង់បានសុវត្ថិភាព និងសុភមង្គលសំរាប់គ្រួសាររបស់ យើង ។ បើយើងសំឡឹងមើលពរជ័យទាំងឡាយដែលយើងមិនរំពឹងទុក នៅក្នុងពេលដែលសេដ្ឋកិច្ចធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រហែលជាឧបសគ្គដែលមនុស្សមួយចំនួនបានប្រឈមមុខនោះ បានបង្រៀនយើងអំពីភាពសុខសាន្តនៃគំនិត សុវត្ថិភាព និងសុភមង្គល ដែលមិនមែនកើតឡើងដោយសារការទិញផ្ទះ ឬអចលទ្រព្យ ដែលធ្វើឱ្យបំណុល កើនឡើងធំជាងប្រាក់សន្សំរបស់យើង ឬប្រាក់ចំណូលតាមលទ្ធភាពរបស់យើង ។

យើងរស់នៅក្នុងពិភពលោកដែលពោរពេញទៅដោយការមិនចេះអត់ធ្មត់ និងសង្កត់ចិត្ត មិនប្រាកដប្រជា និងពេញទៅដោយជម្លោះ។ វាដូចជាសហគមន៍មួយដែលមានការផ្លាស់ប្រែទៅរកសាសនាជាច្រើន ជាកន្លែងដែលយ៉ូសែប ស្ម៊ីធ បានរស់នៅកាលដែលគាត់មានអាយុ 14 ឆ្នាំ ខំស្វែងរកចម្លើយចំពោះសំណួរដែលគាត់មាន។ យុវជន យ៉ូសែបបាននិយាយថា "ការរាប់អានគ្នានោះលែងមានអស់រលីង ដោយសារតែពាក្យឈ្លោះប្រកែក និងការប្រកួតប្រជែងគ្នាខាង គំនិតជឿ "។ 7

សុវត្ថិភាពសំរាប់គ្រួសាររបស់យើងកើតចេញមកពីការរៀនចេះគ្រប់គ្រងខ្លួនឯង ជៀសវាងពីភាពហួសហេតុនៃពិភព លោកនេះ ហើយចូរសង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង។ ភាពសុខសាន្តនៅក្នុងចិត្តកើតមកពីជំនឿដ៏រឹងមាំលើព្រះយេស៊ូវគ្រីស្ទ។ សុភមង្គលកើតមកពីការឧស្សាហ៍ព្យាយាមនៅក្នុងរក្សាសេចក្ដីសញ្ញាដែលបានធ្វើនៅពេលជ្រមុជទឹក និងនៅក្នុងដំណាក់ដ៏បរិសុទ្ធនៃព្រះអម្ចាស់ ។

តើយើងមានគំរូនៃការសង្កត់ចិត្តណាមួយដែលប្រសើរជាង គំរូរបស់ព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទរបស់យើង?

នៅពេលដួងចិត្តរបស់យើងពោរពេញទៅដោយកំហឹង ដោយសារការប្រណាំងប្រជែង និងជម្លោះ ព្រះអង្គសង្គ្រោះបានបង្រៀនយើងថា យើងគួរតែ "ប្រែចិត្តហើយក្លាយទៅដូចជាកូនក្មេង"។8 យើងគួរតែស្រុះស្រួលជាមួយបងប្អូនប្រុសរបស់យើង ហើយត្រឡប់ទៅរកព្រះអង្គសង្គ្រោះដោយគោលបំណងដ៏ពេញលេញនៃបេះដូង។9

ពេលអ្នកផ្សេងមានចិត្តមិនល្អ ព្រះយេស៊ូវបានបង្រៀនថា: "សេចក្ដីសប្បុរសរបស់យើងនឹងមិនដែលឃ្លាតបាត់ពីអ្នកឡើយ"។10

ពេលយើងប្រឈមមុខនឹងទុក្ខវេទនា នោះទ្រង់មានបន្ទូលថា: "ចូរមានចិត្តអត់ធន់ក្នុងការឈឺចាប់ ចូរកុំជេរប្រមាថពួកអ្នកណាដែលជេរប្រមាថឡើយ។ ចូរត្រួតត្រាផ្ទះសំបែងរបស់អ្នកដោយភាពស្លូតបូត ហើយចូរតាំងចិត្តឱ្យបានខ្ជាប់ខ្ជួនចុះ"។11

ពេលយើងត្រូវបានគេជិះជាន់ យើងអាចបានលួងលោមចិត្តដោយសារបានដឹងថា "ទ្រង់ត្រូវគេសង្កត់សង្កិនហើយ ទ្រង់ត្រូវគេធ្វើទុក្ខ តែទ្រង់មិនបានហើបព្រះឱស្ឋសោះ"។12 ទ្រង់បានទ្រាំទ្រវេទនាអស់ទាំងសេចក្ដីឈឺចាប់របស់យើងជាពិត"។13

នៅពេលដែលព្រះយេស៊ូវគ្រីស្ទជាព្រះដ៏មហិមាលើសអ្វីៗទាំងអស់ បានរងទុក្ខចំពោះយើងទាំងអស់គ្នារហូតដល់ចេញលោហិតពីគ្រប់រន្ធញើស ក៏ទ្រង់មិនបង្ហាញពីកំហឹង ឬជេរប្រមាថដោយសារការឈឺចាប់នោះឡើយ។ ជាមួយនឹងការទប់ព្រះទ័យ ឬសង្កត់ចិត្តដ៏លើសលុបព្រះទ័យរបស់ទ្រង់គឺមិនមែនសំរាប់ព្រះអង្គទ្រង់ផ្ទាល់នោះទេ ប៉ុន្តែគឺសំរាប់អ្នក ហើយនិងខ្ញុំ។ បន្ទាប់មក ដោយការបន្ទាបខ្លួន និងពោរពេញទៅដោយសេចក្ដីស្រឡាញ់ ទ្រង់បានមានបន្ទូលថា: "ទោះជាយ៉ាងណាក៏ដោយ សូមព្រះវរបិតាបានសិរីល្អ ហើយយើងបានទទួលទាន និងសម្រេចការរៀបចំរបស់យើងចំពោះ កូនចៅមនុស្ស"។14

ក្នុងអំឡុងពេលឆ្នាំមុននេះ វាគឺជាឯកសិទ្ធរបស់ខ្ញុំក្នុងការថ្លែងទីបន្ទាល់ពីតួអង្គពិតនៃព្រះអង្គសង្គ្រោះរបស់យើង និងការស្តារឡើង-វិញនៃដំណឹងល្អចំពោះពួកបរិសុទ្ធ និងមិត្តភក្តិទាំងឡាយនៅពាសពេញទ្វីបអាស៊ី។ ពួកគេភាគច្រើនគឺជា ជំនាន់ពួកបរិសុទ្ធទីមួយដែលបានរស់នៅពេលដែលសាសនាចក្រទើបតែកកើត។ ការធ្វើដំណើរនៅថ្ងៃចុងក្រោយនៅលើដែនដីកំណើតរបស់ពួកគេត្រូវបានលើកយកមកពិភាក្សា អំពីបទពិសោធន៍ទាំងនោះដោយពួកបរិសុទ្ធថ្ងៃចុងក្រោយ ចំនួនទីមួយកាលពីប៉ុន្មានឆ្នាំកន្លងទៅនោះ។

នៅក្នុងពិភពលោកដ៏អស្ចារ្យ នៃតំបន់អាស៊ីនៅក្នុងភូមិភាគផ្សេងៗគ្នា ជាកន្លែងដែលសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ មានមិនដល់មួយភាគរយនៃចំនួនប្រជាជនសរុបផង បានធ្វើឱ្យខ្ញុំកាន់តែមានសេចក្ដីសារទចំពោះលក្ខណៈដូចព្រះគ្រីស្ទអំពីការសង្កត់ចិត្ត។ ខ្ញុំស្រឡាញ់ ហើយគោរពពួកបរិសុទ្ធទាំងនេះ ដែលបានបង្រៀនដល់ខ្ញុំតាមរយៈគំរូអំពីអត្ថន័យនៃការបន្ទាបខ្លួន និងសេចក្ដីស្រឡាញ់ដ៏ពេញលេញ ដោយ "សង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង ដែលផ្ទុកផ្ដាក់ឱ្យ[ពួកគេ]ថែរក្សា" ។15 តាមរយៈពួកគេ ខ្ញុំបានយល់កាន់តែច្បាស់អំពីសេចក្ដីស្រឡាញ់របស់ព្រះចំពោះកូនចៅរបស់ទ្រង់ ។

ខ្ញុំសូមបន្សល់ទុកនូវទីបន្ទាល់របស់ខ្ញុំថា ព្រះអង្គប្រោសលោះរបស់យើងមានព្រះជន្មរស់ ហើយអំណោយទានដ៏ទេវភាពនៃការសង្កត់ចិត្តរបស់ទ្រង់ គឺកើតមានចំពោះកូនចៅរបស់ព្រះគ្រប់រូប នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. គ. និង ស. 12:8 ។

2. កាឡាទី 5:22-23 ។

3. ទីតុស 1:7-8 ។

4. អាលម៉ា 7:6, 23 ។

5. អាលម៉ា 38:11 ។

6. អាលម៉ា 38:10 ។

7. យ៉ូសែប ស្ម៊ីធ-- ប្រវត្តិ 1:6 ។

8. នីហ្វៃទី 3 11:37 ។

9. សូមមើល នីហ្វៃទី 3 12:24 ។

10. នីហ្វៃទី 3 22:10 ។

11. គ. និង ស. 31:9 ។

12. ម៉ូសាយ 14:7 ។

13. ម៉ូសាយ 14:4 ។

14. គ. និង ស. 19:19 ។

15. គ. និង ស. 12:8 ។